# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការ
ទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
លេខ: ១៤/២៥ គ.ទ.ក ស.ជ.ណ

ថ្ងៃ សុក្រ ១៤រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែមីនា ឆ្នាំ២០២៥

## ជម្រាបជូន
## លោក សាកលវិទ្យាធិការ សាកលវិទ្យាល័យពុទ្ធិសាស្ត្រ

**កម្មវត្ថុ ៖** លទ្ធផលនៃការចុះវាយតម្លៃផ្តល់ការទទួលស្គាល់គុណភាពអប់រំ នៅសាកលវិទ្យាល័យពុទ្ធិសាស្ត្រ។

**យោង ៖**
- ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- សេចក្តីសម្រេចលេខ ០១/១៥ គ.ទ.ក.សសរ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យប្រើប្រាស់ស្តង់ដាជាតិសម្រាប់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា
- សេចក្តីណែនាំលេខ ០១/២៣ គ.ទ.ក. សណន ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំលើគ្រឹស្ថានឧត្តមសិក្សា
- សេចក្តីជូនដំណឹងលេខ ០១/២៤ គ.ទ.ក. សជណ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៤ ស្តីពីការវាយតម្លៃផ្តល់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា
- លិខិតលេខ UP១៦៥៩/២៤ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤ របស់សាកលវិទ្យាល័យពុទ្ធិសាស្ត្រ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **លោក សាកលវិទ្យាធិការ** ជ្រាបថា៖ ដោយយោងលើលទ្ធផលនៃការចុះវាយតម្លៃផ្តល់ការទទួលស្គាល់គុណភាពអប់រំ នៅសាកលវិទ្យាល័យពុទ្ធិសាស្ត្រ ឆ្នាំសិក្សា ២០២៣-២០២៤ គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ពិនិត្យឃើញថា សាកលវិទ្យាល័យពុទ្ធិសាស្ត្របានបំពេញត្រឹមត្រូវភាគច្រើន ស្របតាមលក្ខខណ្ឌតម្រូវនៃស្តង់ដាជាតិទាំង៩ សម្រាប់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា ដោយទទួលបានពិន្ទុមធ្យមភាគ ៨.៧៥។ គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជាសម្រេចផ្តល់ **ការទទួលស្គាល់គុណភាពអប់រំពេញសិទ្ធិ** ដល់សាកលវិទ្យាល័យពុទ្ធិសាស្ត្រ ចាប់ពីឆ្នាំសិក្សា ២០២៣-២០២៤ តទៅ ដោយមានសុពលភាពរយៈពេល ៥ឆ្នាំ។

នៅពាក់កណ្តាលអាណត្តិនៃការទទួលស្គាល់គុណភាពអប់រំពេញសិទ្ធិនេះ សាកលវិទ្យាល័យពុទ្ធិសាស្ត្រ ត្រូវរៀបចំរបាយការណ៍ ស្តីពីវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍ជូនគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ដើម្បីចុះពិនិត្យនិងផ្ទៀងផ្ទាត់។

នៅឆ្នាំសិក្សា ២០២៨-២០២៩ សាកលវិទ្យាល័យពុទ្ធិសាស្ត្រ ត្រូវរៀបចំរបាយការណ៍ស្វ័យវាយតម្លៃ និងស្នើសុំមកគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ដើម្បីចុះវាយតម្លៃផ្តល់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សាសាជាថ្មី។ ៤

អគារលេខ២០១, មហាវិថី ព្រះនរោត្តម, សង្កាត់ បឹងកេងកង១, ខណ្ឌ បឹងកេងកង, រាជធានីភ្នំពេញ, គេហទំព័រ: www.acc.gov.kh, អ៊ីម៉ែល: info@acc.gov.kh, ទូរស័ព្ទ: (៨៥៥)១២ ៧១៩ ៨៨៧

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោក សាកលវិទ្យាធិការ** ជ្រាប និងចាត់ចែងតាមការគួរ។

សូម **លោក សាកលវិទ្យាធិការ សាកលវិទ្យាល័យពុទ្ធិសាស្ត្រ** ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ

**ប្រធាន គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា**

**ចម្លងជូន៖**
- អគ្គនាយកដ្ឋានឧត្តមសិក្សា
- ខុទ្ទកាល័យលោកបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
- ក្រសួង-ស្ថាប័នពាក់ព័ន្ធ

  "ដើម្បីជ្រាបជាព័ត៌មាន"
- កាលប្បវត្តិ
- ឯកសារ គ.ទ.ក.

**បណ្ឌិតសភាចារ្យ មាន់ជួន ណារ៉ុន**